00617310

លេខ/No: D427/5/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស-(អ.ប.ជ ១៥៤)
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គបុរេជំនុំជម្រះ
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១០

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ: សាធារណៈ / Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងដីកាដំណោះស្រាយ**

---

<u>ដាក់ដោយ</u>៖
**សហមេធាវីរបស់លោក អៀង សារី៖**
អាង ឧត្តម
Michael G. KARNAVAS

<u>ផ្ញើជូន</u>៖
**ចៅក្រមអង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា៖**
ជា លាង
Andrew CAYLEY

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 22 / 10 / 2010
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

យោងតាមវិធាន ៧៤(៣)(ច) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន") លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនៅក្នុងដីកាដំណោះស្រាយ ដែលបានសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរហូតដល់គាត់មានវត្តមាន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ ក.ស.ច.ស មិនបានចេញសេចក្តីសម្រេច មានសំអាងហេតុជាក់លាក់មួយដោយឡែកអំពីមូលហេតុ ដែលតម្រូវឲ្យមានការបន្តថិរវេលានៃការឃុំខ្លួននោះទេ ព្រមទាំងមានការភ័ន្តច្រឡំក្នុងការកំណត់ថា លក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន ដូចមានចែងនៅក្នុងវិធាន ៦៣(៣) នៅតែត្រូវបានបំពេញ។ ដោយសារតែបញ្ហានេះជាបញ្ហាដែលប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់លោក លោក អៀង សារី ក្នុងការទទួលបានសេរីភាពនោះ មេធាវីការពារសូមស្នើសុំឲ្យមានការបើកសវនាការដេញដោលផ្ទាល់មាត់។

## I. ឧទ្ទិករណ៍សង្ខេប

១. មេធាវីការពារនឹងបង្ហាញថា៖

ក. ក.ស.ច.ស មិនបានបំពេញតាមលក្ខខណ្ឌនៅក្នុងវិធាន៦៨ ដែលចែងថា ការបន្តថិរវេលា នៃការឃុំខ្លួនត្រូវតែធ្វើឡើង តាមរយៈការចេញសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក។

ខ. បើទោះជាដីកាដំណោះស្រាយត្រូវបានចាត់ទុកថា មានសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក ដែលតម្រូវឲ្យមានការបន្តការឃុំខ្លួនលោក អៀង សារី ក៏ដោយ ក៏ការឃុំខ្លួនលោក អៀង សារី មិនត្រូវមានបន្តទៀតនោះទេ ព្រោះថា ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការសម្រេចថា ការបន្តការឃុំខ្លួនគឺជាការចាំបាច់៖

(១) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការធានានូវវត្តមានរបស់លោក អៀង សារី នៅពេលជំនុំជម្រះឡើយ។

(២) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការការពារសន្តិសុខរបស់ លោក អៀង សារី ឡើយ។

(៣) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈឡើយ។

---

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427, ERN: 00604508-00605246, កថាខណ្ឌ១៦២២-២៤។

## II. ច្បាប់ដែលពាក់ព័ន្ធ

### ក. សិទ្ធិទទួលបានសេរីភាព និងសច្ចាធារណ៍នៃនិរទោស

២. យោងតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[2] “ជនគ្រប់រូបមានសិទ្ធិរស់រាន មានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន”។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ធានាឲ្យមានសច្ចាធារណ៍នៃនិរទោស។ “ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ”[3]។

៣. សិទ្ធិជាមូលដ្ឋាន ទទួលបានសេរីភាពនិងទទួលបានសច្ចាធារណ៍នៃនិរទោស ក៏ត្រូវបានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ដែលបទដ្ឋានទាំងនេះត្រូវតែគោរពយ៉ាងពេញលេញដោយ អ.វ.ត.ក[4]។ មាត្រា ៩(៣) នៃ ICCPR ចែងមួយផ្នែកថា “<u>វាមិនមែនជាវិធានទូទៅទេ ដែលថានរណាម្នាក់ត្រូវតែបានឃុំខ្លួនដើម្បីរង់ចាំការជំនុំជម្រះនោះ</u> ប៉ុន្តែអ្វីដែលជាវិធានទូទៅគឺការឲ្យនៅក្រៅឃុំ ដោយមានការធានាឲ្យចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម”[5]។ មាត្រា ១៤(២) នៃ ICCPR ចែងថា “ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់”។

៤. គោលការណ៍មូលដ្ឋានទាំងនេះក៏ត្រូវបានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ វិធាន ២១(១)(ឃ) ចែងថា “ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់ជននោះមិនទាន់ត្រូវបានរកឃើញ”។ វិធាន ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

---

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលត្រូវបានវិសោធនកម្មថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩។

[3] *ដូចជើងទំព័រខាងលើ។*

[4] យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។ *ដូចជើងទំព័រខាងលើ។* យោងតាមមាត្រា១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី”។

[5] គូសបញ្ជាក់បន្ថែម។

ចែងថា "ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ"។

៥. នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") សម្រេចថា គោលការណ៍ទាំងនេះត្រូវមានលក្ខណៈកំហិតតែ៖

> ដើម្បីបម្រើឲ្យ "គោលបំណងសំខាន់មានលក្ខណៈគ្រប់គ្រាន់" ហើយត្រូវ "ឲ្យមានការប៉ះពាល់ដល់សិទ្ធិនេះ ... តែក្នុងកម្រិតចាំបាច់មួយ ដើម្បីតែសម្រេចបាននូវគោលបំណងសំខាន់នេះតែប៉ុណ្ណោះ" ... ICTY បានអនុវត្តតាម "គោលការណ៍ទូទៅមួយស្ដីពីសមាមាត្រ" ក្នុងការវាយតម្លៃភាពសក្ដិសមរបស់ចុងចោទដើម្បីទទួលបានការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ដោយកត់សម្គាល់ថា ការកំហិតសិទ្ធិមានសេរីភាពជាមូលដ្ឋាន អាចទទួលយកបាន តែនៅពេលដែល "(១) សក្ដិសម (២) ចាំបាច់ និងនៅពេលដែល (៣) កម្រិត និងវិសាលភាពនៃការកំហិតសិទ្ធិនេះ ស្ថិតនៅក្នុងទំនាក់ទំនងដ៏សមហេតុផលមួយទៅនឹងគោលដៅដែលបានកំណត់នោះ"[6]។

៦. ទោះជាសិទ្ធិមានសេរីភាព និងសច្ចាធារណ៍នៃនិរទោសមានសារៈសំខាន់ក៏ដោយ ការឃុំខ្លួនត្រូវបានធ្វើយុត្តិកម្ម[7] នៅតាមបណ្ដាតុលាការអន្តរជាតិដោយសំអាងលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ និងលើមូលហេតុថា តុលាការអន្តរជាតិមិនមានសមត្ថកិច្ចអនុវត្តដីកាចាប់ខ្លួនដោយខ្លួនឯង តែត្រូវពឹងផ្អែកលើអាជ្ញាធរមូលដ្ឋានដើម្បីអនុវត្តភារកិច្ចជំនួសឲ្យតុលាការ[8]។ ទោះជាយ៉ាងនេះក្ដី តុលាការអន្តរជាតិបានប្រកាន់ភ្ជាប់ថា "ការឃុំខ្លួនគឺជាវិធានការធ្ងន់ធ្ងរបំផុតដែលអាចយកមកអនុវត្តចំពោះជនជាប់ចោទ និងត្រូវយកមកប្រើ តែនៅពេលដែលគ្មានវិធានការណាផ្សេងពីនេះអាចយកមកអនុវត្តបានដើម្បីទទួលបាននូវប្រសិទ្ធភាពដូចការឃុំខ្លួន បើទោះជាគោលការណ៍នេះ

---

[6] *រឿងក្ដី MiloÈević តទល់ រដ្ឋអាជ្ញា,* IT-02-54-AR73.7, សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្កំ នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការចាត់តាំងក្រុមមេធាវីការពារក្ដី, ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤, កថាខណ្ឌ១៧។

[7] "គោលការណ៍ដែលគាំទ្រការដោះលែងបណ្ដោះអាសន្ន គឺជាការធ្វើឡើងតាមធម្មជាតិនៃការសន្មតជាមុនថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោស។ ក្នុងចំណោមបញ្ហាផ្សេងៗទៀត ដើម្បីបន្តថាជនជាប់ចោទមិនមានទោសមានន័យថា ការដាក់ទណ្ឌកម្មមិនអាចធ្វើបានទេ រហូតទាល់តែជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពសិន។ <u>ដូច្នេះ ការឃុំខ្លួនត្រូវឆ្លើយតបទៅនឹងគោលបំណងជាក់លាក់មួយចំនួនផ្សេងទៀត</u>"។ Daniel J. Rearick, *Innocent Until Alleged Guilty: ឥតកំហុសរហូតមានទោសដូចការចោទប្រកាន់៖ ការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ននៅតុលាការ ICTR,* 47 HARV. INT"L L.J. 577, 577 (2003) (គូសបញ្ជាក់បន្ថែម)។

[8] *រឿងក្ដី រដ្ឋអាជ្ញា តទល់ Bradanin & Talić,* IT-99-36, សេចក្ដីសម្រេចលើ ញត្តិរបស់ Radoslav Brdanin សុំដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០, កថាខណ្ឌ១៨ ។

មិនរារាំងឲ្យមានការអនុវត្តការឃុំខ្លួន នៅក្នុងករណីសមស្របណាមួយក៏ដោយ”[9]។

៧. អ.វ.ត.ក ដែលជាតុលាការក្នុងស្រុកមួយបង្កើតឡើងក្រោមប្រព័ន្ធតុលាការជាតិ មិនមានការព្រួយបារម្ភដូចទៅនឹងតុលាការអន្តរជាតិទាំងនោះ ទាក់ទងទៅនឹងកង្វះខាតសមត្ថកិច្ចក្នុងការអនុវត្តដីកាចាប់ខ្លួននោះទេ។ អ.វ.ត.ក មាននគរបាលយុត្តិធម៌ ដែលជាអ្នកមានសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការអនុវត្តដីកាចាប់ខ្លួន[10]។

៨. ក.ស.ច.ស បានដឹងថា “ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការពិសេស ចំពោះវិធានទូទៅនៃសិទ្ធិមានសេរីភាពនៅដំណាក់កាលមុនការជំនុំជម្រះ”[11]។ ដោយសារតែសិទ្ធិជាមូលដ្ឋានទាំងនេះកំពុងមានហានិភ័យ និងដោយសារតែភាពធ្ងន់ធ្ងរនៃការអនុវត្តវិធានការឃុំខ្លួន ការសម្រេចប្រើប្រាស់វិធានការឃុំខ្លួន ដោយយោងទៅលើវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង ត្រូវតែធ្វើឡើងដោយពិចារណាឲ្យបានហ្មត់ចត់ទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗទៀត និងយុត្តិសាស្ត្រអន្តរជាតិដែលមានស្រាប់។

**ខ. វិធានផ្ទៃក្នុងដែលពាក់ព័ន្ធ**

៩. វិធាន ៦៣(៣) ចែងថា៖

---

[9] VLADIMIR TOCHILOVSKY, JURISPRUDENCE OF THE INTERNATIONAL CRIMINAL COURTS AND THE EUROPEAN COURT OF HUMAN RIGHTS 621 (បោះពុម្ព ២០០៨ ដោយ Martinus Nijhoff), *ទាញហេតុសំអាង, រឿងក្តីរដ្ឋអាជ្ញា តទល់ BoÈkoski & Tarčulovski,* IT-04-82-PT, សេចក្តីសម្រេចលើពាក្យសុំលើកទីពីរសម្រាប់ការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន, ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦, កថាខណ្ឌ១៨។ ជាភស្តុតាងនៃភាពត្រឹមត្រូវនៃវិធានការណ៍នេះ កត់សម្គាល់លើសុន្ទរកថាដែលធ្វើឡើងនាពេលថ្មីៗដោយការិយាល័យរដ្ឋបាល (Registra) នៅសិក្ខាសាលាការទូតរបស់តុលាការ ICTY ធ្វើនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ ដែលគាត់បានពិភាក្សាពីផលប៉ះពាល់មិនល្អនៃបរិដ្ឋានមន្ទីរឃុំឃាំងទៅលើសុខភាពអ្នកជាប់ឃុំ។ “ខណៈដែល UNDU គឺជាស្ថាប័នមួយ ដែលថិរវេលាមធ្យមនៃការឃុំខ្លួនយូរជាងថិរវេលានៃយុត្តាធិការជាតិ ហើយស្ទើរតែដូចគ្នានឹងពន្ធនាគារមួយចំនួនទៅហើយ ...។ បញ្ហានេះដោយមិនអាចជៀសវាងបាន មានផលប៉ះពាល់ដែលធ្វើឲ្យខូចប្រយោជន៍ [Sic] លើស្ថានភាពផ្លូវចិត្តអ្នកជាប់ឃុំ...”។

[10] វិធាន ៤៥(២)។

[11] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C22/8, ERN: 00399377-00399388, កថាខណ្ឌ១០។

សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និង

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការ ដ៏ចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ។

១០. ដូចនេះ វិធាន ៦៣(៣) បានកំណត់លក្ខណៈវិនិច្ឆ័យជាពីរផ្នែក ដើម្បីកំណត់ថាតើអាចឱ្យមានដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នដែរឬទេ។ លក្ខខណ្ឌនៅក្នុងផ្នែក "ក" ត្រូវបំពេញឱ្យបានជាមុនសិន មុននឹងកំណត់ថា លក្ខខណ្ឌណាមួយនៅក្នុងផ្នែក "ខ" ត្រូវបានបំពេញនោះ។ យ៉ាងណាក៏ដោយ ទោះជាលក្ខណៈវិនិច្ឆ័យនៅក្នុងផ្នែកទាំងពីរត្រូវបានបំពេញក៏ដោយ វិធាន ៦៣(៣) ផ្តល់ឱ្យ ក.ស.ច.ស នូវឆន្ទានុសិទ្ធិដើម្បីសម្រេចមិនចេញដីកាឱ្យឃុំខ្លួនបណ្តោះអាសន្នបានដែរ។ ការផ្តល់ឆន្ទានុសិទ្ធិឱ្យទៅ ក.ស.ច.ស នេះ បង្ហាញយ៉ាងច្បាស់តាមរយៈការប្រើប្រាស់ពាក្យពេចន៍នៅក្នុងវិធាននេះ នោះគឺ៖ "សហចៅក្រមស៊ើបអង្កេត <u>អាច</u> ចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន..."[12]។

១១. វិធាន ៦៨(១) ចែងថា៖

ការចេញដីកាដំណោះស្រាយ មានអនុភាពបញ្ចប់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និង ដីកាសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅពេលដែលរយៈពេលកំណត់នៅក្នុងការប្តឹងឧទ្ធរណ៍ត្រូវផុតរលត់។ ប៉ុន្តែនៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខណ្ឌទាំងឡាយសម្រាប់បង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ឬឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការក្រោមវិធាន៦៣ និង ៦៥ នៅតែតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតអាចសម្រេចបន្តឃុំជនជាប់ចោទបណ្តោះអាសន្នតទៅទៀត ឬរក្សាលក្ខខណ្ឌ

[12] គូសបញ្ជាក់បន្ថែម។

នៃការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះជនជាប់ចោទដដែល នៅក្នុងសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក នៅក្នុងដីកាដំណោះស្រាយ រហូតដល់ជនជាប់ចោទនេះត្រូវនាំខ្លួនទៅជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង[13]។

## III. ឧឡារិករណ៍

### ក. ក.ស.ច.ស មិនបានបំពេញតាមលក្ខខណ្ឌក្នុងវិធាន ៦៨ ដែលចែងថា ការបន្តថិរវេលានៃការបន្តឃុំខ្លួនបណ្តោះអាសន្នត្រូវតែកំណត់ដោយសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក

១២. វិធាន៦៨ ចែងថា ការចេញដីកាដំណោះស្រាយអាចមានអនុភាពបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នបាន លុះត្រាតែ ក.ស.ច.ស មាន "សេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក" នៅក្នុងដីកាដំណោះស្រាយ ដោយពន្យល់អំពីលក្ខខណ្ឌផ្សេងៗតម្រូវឱ្យមានការឃុំខ្លួនតាមវិធាន៦៣ ដែលនៅតែជាមានលក្ខណៈសមស្រប។ ក.ស.ច.ស មិនបានធ្វើបែបនេះទេ។ ផ្នែកនៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងការបន្តការឃុំខ្លួនមានតែ ៣ កថាខណ្ឌប៉ុណ្ណោះ ហើយមិនបានផ្តល់ជាសេចក្តីសម្រេចមានសំអាងហេតុ ដែលបញ្ជាក់មូលហេតុថាការឃុំខ្លួននៅតែជាការចាំបាច់នៅឡើយ។ កថាខណ្ឌនៅក្នុងដីកាចែងថា៖

> ដោយយល់ឃើញថា ដោយផ្អែកលើបទចោទដែលមាននៅក្នុងដីកានេះ ក្នុងការផ្តល់ យុត្តិកម្មដល់ការបញ្ជូនខ្លួន **ជា អៀង សារី អៀង ធីរិទ្ធ** និង**ខៀវ សំផន** ទៅអង្គជំនុំជម្រះ លក្ខខណ្ឌដែលបានកំណត់ដោយវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ។
>
> យល់ឃើញថា ទាក់ទិននឹងលក្ខខណ្ឌដែលតម្រូវដោយវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ... សាលដីកាចុងក្រោយរបស់អង្គបុរេជំនុំជម្រះដែលសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ **អៀង សារី អៀង ធីរិទ្ធ** និង**ខៀវ សំផន** នៅតែរក្សាតម្លៃរបស់ខ្លួនដដែល ហើយចំណុចថ្មី ដែលមានតែមួយគត់គឺ ការចោទប្រកាន់ទៅលើអ្នកទាំងនោះ ដែលនេះរឹតតែធ្វើឱ្យសំអាង ហេតុដែលមាននៅក្នុងដីកាកន្លងមកកាន់តែមានលក្ខណៈរឹងមាំ និងធ្វើឱ្យការឃុំខ្លួនរឹតតែ មានភាពចាំបាច់ជាងពេលណាៗទាំងអស់។
>
> ហេតុនេះ យល់ឃើញថា ការបន្តការឃុំខ្លួនជនជាប់ចោទរហូតដល់ពេលនាំខ្លួនទៅជំនុំ ជម្រះនៅអង្គជំនុំជម្រះសាលាដំបូង ដោយអនុវត្តតាមវិធាន ៦៨ នៃវិធានផ្ទៃក្នុង គឺជាការចាំបាច់... ទាក់ទងនឹង **អៀង សារី** ដើម្បីធានាថា ជនជាប់ចោទនឹងមានវត្តមាននៅពេលជំនុំជម្រះ ការពារសន្តិសុខដល់ជនជាប់ចោទ

---

[13] គូសបញ្ជាក់បន្ថែម។

រក្សាសណ្តាប់ធ្នាប់សាធារណៈ...[14]

១៣. ដីកាដំណោះស្រាយពិតជាបានយោងទៅសំអាងហេតុពីមុន ប៉ុន្តែគ្រាន់តែលើកឡើងជាទូទៅ ហើយក៏មិនបានពន្យល់អំពីមូលហេតុថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាការចាំបាច់ បើទោះជានៅពេលពិចារណាទៅលើការកន្លងផុតទៅនៃពេលវេលាក៏ដោយ។ ការដែលគ្រាន់តែសរសេរមូលដ្ឋានបីចំណុច ក្នុងចំណោមមូលដ្ឋានប្រាំចំណុចក្នុងការឃុំខ្លួនបណ្តោះអាសន្នតាមវិធាន ៦៣ (៣) មិនមានភាពគ្រប់គ្រាន់ បង្កើតបានជាសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក ដើម្បីបញ្ជាក់ពីមូលហេតុដែលលោក អៀង សារី ចាំបាច់ត្រូវបន្តរងការឃុំខ្លួនទៀតនោះទេ។

**ខ. បើទោះជាដីកាដំណោះស្រាយត្រូវបានចាត់ទុកថាមានសេចក្តីសម្រេចមានសំអាងហេតុជាក់លាក់មួយដោយឡែក ដែលតម្រូវឱ្យបន្តថិរវេលានៃការឃុំខ្លួនលោក អៀង សារី ក៏ដោយ ក៏ការឃុំខ្លួនគាត់ មិនត្រូវបន្តទៀតដែរ ពីព្រោះ ក.ស.ច.ស មានការភ័ន្តច្រឡំក្នុងការសម្រេចថា ការបន្តការឃុំខ្លួនគឺជាការចាំបាច់**

១៤. លោក អៀង សារី មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសេរីភាព និងសច្ចាធារណ៍នៃនិរទោស។ គាត់មិនត្រូវទទួលរងការឃុំខ្លួនឡើយ លើកលែងតែការឃុំខ្លួនគឺជាការចាំបាច់ដោយខានមិនបាន។ នៅក្នុងករណីនេះ ក.ស.ច.ស មានការភ័ន្តច្រឡំនៅក្នុងការតម្រូវឱ្យបន្តការឃុំខ្លួនលោក អៀង សារី ជាបណ្តោះអាសន្ន ពីព្រោះថា លក្ខខណ្ឌនៅក្នុងវិធាន៦៣(៣) មិនទាន់ត្រូវបានបំពេញទេ។

**(១) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការធានាថា ជនជាប់ចោទមានវត្តមាននៅពេលជំនុំជម្រះ**

១៥. ក.ស.ច.ស មានការភ័ន្តច្រឡំដោយមិនបានពិចារណាឱ្យបានពេញលេញចំពោះស្ថានភាពនាពេលបច្ចុប្បន្ននេះ។ លោក អៀង សារី មានអាយុ ៨៦ ឆ្នាំ ហើយគាត់មានបញ្ហាសុខភាពទន់ខ្សោយខ្លាំងដែលប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពក្នុងការធ្វើដំណើរផ្លាស់ទីរបស់គាត់[15]។ គាត់អាចដើរយ៉ាង

---

[14] ដីកាដំណោះស្រាយ កថាខណ្ឌ១៦២-២៤។

[15] *សូមមើលឧទាហរណ៍, រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, លិខិតរបស់មន្ទីរឃុំឃាំង អ.វ.ត.ក ផ្ញើជូន ក.ស.ច.ស ស្តីពីស្ថានភាពសុខភាពរបស់ជនត្រូវចោទ អៀង សារី, ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ B31, ERN: 00369424-00369425; *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំឱ្យដំឡើងបង្កាន់ដៃនៅក្នុងបន្ទប់ឃុំឃាំងរបស់លោក អៀង សារី, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩; *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំឱ្យធ្វើការជួបសម្ភាសជាមួយលោក អៀង សារី នៅថ្ងៃ ទី១១ ខែសីហា ឆ្នាំ២០០៩ នៅបន្ទប់ឃុំឃាំងនៃមន្ទីរឃុំឃាំង, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។ "ដូចមានចែងនៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពសុខភាពរបស់ជនត្រូវចោទ អៀង សារី ដែលបំពេញដោយប្រធានមន្ទីរឃុំឃាំង កាលពីថ្ងៃទី២៨

លំបាក ដូច្នេះគាត់មិនអាចរត់គេចខ្លួនបានទេ។ គាត់មានគ្រួសាររស់នៅក្នុងប្រទេសកម្ពុជា។ ភរិយារបស់គាត់ លោកស្រី អៀង ធីរិទ្ធ ជាប់នៅក្នុងមន្ទីរឃុំឃាំងនៅឡើយ។ គាត់បានលើកឡើងនៅក្នុងសវនាការលើកមុនស្ដីពីលក្ខខណ្ឌនៃការឃុំខ្លួនថា គាត់មានបំណងនៅថែទាំភរិយារបស់គាត់នៅពេលភរិយាគាត់ស្រែកយំ[16]។ វាជាការលំបាកជឿថា គាត់អាចរត់គេចចេញពីប្រទេស និងចាកឆ្ងាយពីភរិយាគាត់ណាស់។ ប្រសិនបើគាត់លែងជាប់ឃុំ គាត់នឹងមកសួរសុខទុក្ខភរិយាគាត់ជាញឹកញាប់ ដូចជាក្រុមគ្រួសារភរិយាគាត់បានធ្វើយ៉ាងដូច្នេះដែរ។ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ក្នុងការធានាឱ្យលោក អៀង សារី មានវត្តមាននៅអង្គជំនុំជម្រះនោះ អង្គបុរេជំនុំជម្រះអាចចាត់វិធានការ ដែលមិនសូវតឹងរ៉ឹង ដូចជាការឃុំខ្លួននៅក្នុងផ្ទះជាដើម។

**(២) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការការពារសន្តិសុខរបស់ អៀង សារី ទេ**

១៦. ក.ស.ច.ស មិនបានផ្ដល់សំអាងហេតុថ្មីៗដែល ស.ច.ស យល់ថា ចាំបាច់ត្រូវឃុំខ្លួនលោក អៀង សារី បន្តទៀត ដើម្បីការពារសន្តិសុខដល់គាត់នោះទេ។ អ.វ.ត.ក អាចមានវិធានការជាច្រើន ដូចជា ការដាក់បុគ្គលិកសន្តិសុខឱ្យយាមគាត់ ដែលនេះជាវិធានការអាចកាត់បន្ថយកង្វល់នេះ។ តាមពិតទៅ អ.វ.ត.ក មានបុគ្គលិកសន្តិសុខជាច្រើនសម្រាប់ការពារបុគ្គលិកតុលាការ។ ការឃុំខ្លួនក្នុងផ្ទះគឺជាជម្រើសមួយផ្សេងទៀត ដែលអាចធានានូវសុវត្ថិភាពរបស់គាត់។ ក.ស.ច.ស មិនបានពន្យល់មូលហេតុដែលខ្លួនមិនជ្រើសរើសយកវិធានការដែលស្រាលជាងការឃុំខ្លួន ក្នុងខណៈដែលលោក អៀង សារី ទទួលបានសច្ចាធារណ៍នៃនិរទោស ហើយគាត់មិនយល់ថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ក្នុងការការពារសុវត្ថិភាពគាត់នោះទេ។

**(៣) ការឃុំខ្លួនមិនមែនជាការចាំបាច់ក្នុងការរក្សាសណ្ដាប់ធ្នាប់សាធារណៈឡើយ**

---

កក្កដា ២០០៩ ហើយនឹងលិខិតថ្មីៗ ក្រោយមកទៀតរបស់យើងខ្ញុំផ្ញើទៅកាន់ ក.ស.ច.ស ទាក់ទងនឹងការតំឡើងនូវបង្កាន់ដៃនៅក្នុងបន្ទប់ឃុំឃាំងរបស់កូនក្ដីយើងខ្ញុំ លោក អៀង សារី បច្ចុប្បន្នកំពុងទទួលរងជំងឺខ្នងយ៉ាងធ្ងន់ធ្ងរ។ បញ្ហានេះបណ្ដាលឱ្យគាត់មិនអាចមានលទ្ធភាពក្រោកឈរ ឬអង្គុយបានដោយខ្លួនឯង ដោយមិនមានអ្នកជួយបានឡើយ" *រឿងក្ដី អៀង សារី* សំណុំរឿង លេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំឱ្យធ្វើការជួបសម្ភាសជាមួយលោក អៀង សារី នៅថ្ងៃទី១១ ខែ សីហា ឆ្នាំ២០០៩ នៅបន្ទប់ឃុំឃាំងនៃមន្ទីរឃុំឃាំង, ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ៣។

[16] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, កំណត់ហេតុនៃការសាកសួរ ទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១០, ឯកសារ C60, ERN: 00495277-00495279, ទំព័រ២។ *រឿងក្ដី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, កំណត់ហេតុនៃការសាកសួរទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន, ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១០, ឯកសារ C64, ERN: 00581370-00581372, ទំព័រ២។

១៧. ក.ស.ច.ស និងអង្គបុរេជំនុំជម្រះបានសម្រេចពីពេលមុនថា ការឃុំខ្លួនលោក អៀង សារី គឺជាការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។ ក.ស.ច.ស បានលើកឡើងពីមុនមកថា វានៅតែជាការចាំបាច់ក្នុងការឃុំខ្លួនតទៅទៀត ដោយសារតែការកន្លងផុតទៅនៃពេលវេលាមិនបានបន្ថយការប៉ះពាល់នៃរបបកម្ពុជាប្រជាធិប្បតេយ្យមកលើសង្គមឡើយ[17]។ មកដល់ពេលនេះ ស្ថានភាពមានការប្រែប្រួលដោយសារតែ ឌុច ត្រូវបានផ្តន្ទាទោស ហើយ លោកនួន ជា លោកខៀវ សំផន លោក អៀង សារី និងលោកស្រី អៀង ធីរិទ្ធ សុទ្ធត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ។ សាធារណជនជឿថា ដំណើរការតុលាការកំពុងបោះជំហានទៅមុខ ហើយសង្គមកម្ពុជាអាចរៀនសូត្រពីអតីតកាល និងចាប់ផ្តើមដំណើរការផ្សះផ្សា។ សណ្តាប់ធ្នាប់សាធារណៈនឹងមិនរងការប៉ះពាល់ ដោយសារតែការដោះលែង លោក អៀង សារី ឡើយ ដោយសារសាធារណជនដឹងថា តុលាការមានផែនការធ្វើសវនាការជំនុំជម្រះក្តី នៅដើមឆ្នាំក្រោយ ហើយបានឃើញថា ចារីនៃឧក្រិដ្ឋកម្មក្នុងអំឡុងពេលខ្មែរក្រហម ដូចជា ឌុច ត្រូវបានទទួលរងការផ្តន្ទាទោសរួចហើយ។

១៨. ដូចដែលបានថ្លែងជាកង្វល់នាពេលថ្មីៗនេះដោយលោក Surya Subedi ដែលជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពី ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាថា "ទស្សនាទាន នៃ "ការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ គួរត្រូវកំណត់ដោយច្បាប់ និងតុលាការក្នុងន័យចង្អៀតបំផុតតាមតែអាចធ្វើទៅបាន ... ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចៅក្រមគួរចង្អុលបង្ហាញនូវពាក្យពេចន៍ពិតប្រាកដថាតើ [សណ្តាប់ធ្នាប់សាធារណៈនឹងត្រូវបានគំរាមកំហែង] យ៉ាងដូម្តេច"។ ការអះអាងនានាដែលបានធ្វើឡើងនៅក្នុងន័យអរូបីមិនគួរត្រូវបានយកមកប្រើប្រាស់ដោយតុលាការឡើយ"[18]។

## IV. សំណូមពរ

**អាស្រ័យដូចហេតុផលដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ** មេធាវីការពារក្តីសូមស្នើដោយក្តីគោរពឲ្យអង្គបុរេជំនុំជម្រះ**បដិសេធ** ការបន្តថិរវេលានៃការឃុំខ្លួន ដែលបានសម្រេចនៅក្នុងដីកាដំណោះស្រាយ

---

[17] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C22/8, ERN: 00399377-00399388, កថាខណ្ឌ២៥។

[18] Surya P. Subedi របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ឯកសារ UN Doc. No. A/HRC/15/46, ចុះថ្ងៃទី ១៦ កញ្ញា ២០១០ កថាខណ្ឌ ៩៩។

00617320



និងបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នលើលោក អៀង សារី។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកបណ្ដឹងឧទ្ធរណ៍នេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២២** ខែតុលា ឆ្នាំ២០១០

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**